ទៀត ការអធិប្បាយនៃអ្នកទទួលច្បាប់ (=និយមន័យនៃដែនកំណត់បុគ្គលនៃច្បាប់) ត្រូវតែធានាថា ពុំមានការលើកលែងដែលគ្មានហេតុផលត្រឹមត្រូវនៃច្បាប់ចំពោះក្រុមមនុស្សណាមួយឡើយ ។

ឧទាហរណ៍:

យោងតាមនិយមន័យដែលកំណត់នៅក្នុងមាត្រា៤ នៃពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ "ជនស៊ីវិល" គឺជាពលរដ្ឋទាំងឡាយណាដែលមិនមែនជា "មន្ត្រី" ឬ"សមាជិកកងកម្លាំងឯកសណ្ឋាន" ។ ដោយការហាមឃាត់មិនឱ្យកាន់កាប់ ឬប្រើប្រាស់អាវុធ គ្រប់ប្រភេទ (មាត្រា៥ នៃពង្រាងច្បាប់នេះ) អនុវត្តចំពោះតែ "ជនស៊ីវិល" នោះមានន័យថា សំរាប់"មន្ត្រី" មានការលើកលែងយ៉ាងខ្លាំងពីការហាមឃាត់នេះ ។ ប្រការនេះ ចោទជាសំនួរថាតើហេតុអ្វីបានជាជាទូទៅមន្ត្រីអាចកាន់កាប់ និងប្រើប្រាស់អាវុធបាន? តើពិតជាមានភាពខុសគ្នាដ៏ធំបែបនេះរវាងជនស៊ីវិល និងមន្ត្រីពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធ ដែលការប្រព្រឹត្តិមិនស្មើភាពនៃក្រុមមួយបែបនេះ ត្រូវបានធ្វើដោយយុត្តិធមិឬ? ទេ វាមិនមែនជាតំរូវការទូទៅសំរាប់មន្ត្រី ដូចជា អ្នកយាមគុក ឬប៉ូលីសតុលាការ ដែលមានភារកិច្ចពិសេសជាប់ខ្លួននៅក្នុងការអនុវត្តន៏ច្បាប់ អាចត្រូវការប្រើអាវុធ ដើម្បីដឹកនាំការិយាល័យរបស់ពួកគេឱ្យបានត្រឹមត្រូវនោះទេ ។

## II) សិទ្ធិ និងករណីយកិច្ច

### ១) ការកាត់បន្ថយសិទ្ធិមនុស្ស ដោយសារការអធិប្បាយពីសិទ្ធិតូចចង្អៀតពេក

បញ្ហានៅក្នុងផ្នែកនេះ ក៏ដូចជាផ្នែកទាំងអស់ផ្សេងទៀតនៃច្បាប់ដែរ អាចបណ្តាលមកពីការប្រើពាក្យមិនច្បាស់លាស់ ។ ពាក្យមិនច្បាស់លាស់ធ្វើឱ្យចំហដោយមិនដឹងថា តើដែនកំណត់នៃសិទ្ធិ និងករណីយកិច្ចមានទំហំប៉ុណ្ណា ឬដូចម្តេចឡើយ ។ ទំហំនៃសិទ្ធិមនុស្សដ៏ពិតប្រាកដ អាចត្រូវបានធ្វើឱ្យខ្ចីដោយសារការអធិប្បាយមិនច្បាស់លាស់ និងមិនគ្រប់គ្រាន់អំពីសិទ្ធិនេះនៅក្នុងអត្ថបទច្បាប់ ។

ឧទាហរណ៍:

សូមស្រមៃដល់ច្បាប់ស្តីពីសន្តិសុខសាធារណៈមួយដែលចែងថា "ក្រុមនីមួយៗដែលមានសមាជិកច្រើនបំផុតចំនួន ១០នាក់ និងប្រធានដែលត្រូវបានជ្រើសតាំងម្នាក់ មានសិទ្ធិជួបប្រជុំគ្នាដោយសេរីនៅក្នុងកន្លែងសាធារណៈមួយ" ។ ច្បាប់បែបនេះ ផ្តល់នូវការអធិប្បាយតូចចង្អៀតពេកអំពីដែនកំណត់នៃសេរីភាពនៃការប្រមូលផ្តុំ ។ វាបានកាត់បន្ថយនូវសិទ្ធិនេះ ពីព្រោះ គ្រាន់តែក្រុមដ៏តូចមួយដែលមានសមាជិកត្រឹមពីរ ឬបីនាក់ក៏មានសិទ្ធិជួបប្រជុំ និងប្រមូលផ្តុំគ្នាបានដែរ ។ម្យ៉ាងវិញទៀត សេរីភាពនៃការប្រមូលផ្តុំគ្នា អាចទាមទារបានដោយក្រុមប្រជាជនណាមួយ ដោយពុំចាំបាច់មានការជ្រើសតាំងប្រធានណាម្នាក់ឡើយ ។

### ២) ការការពារសិទ្ធិមិនគ្រប់គ្រាន់

បញ្ហានោះក៏អាចកើតមានផងដែរថា ពង្រាងអត្ថបទច្បាប់នោះមិនផ្តល់សិទ្ធិគ្រប់គ្រាន់ ដើម្បីការពារសិទ្ធិមនុស្ស របស់បុគ្គលម្នាក់ឱ្យបានគ្រប់គ្រាន់ ។

ឧទាហរណ៍:

ពង្រាងច្បាប់ជលផល មិនទទួលស្គាល់សិទ្ធិរបស់សហគមន៍នេសាទក្នុងការអនុវត្តន៏ សកម្មភាពពង្រឹងការអនុវត្តន៏ច្បាប់ដោយខ្លួនគេផ្ទាល់នៅក្នុងករណីបន្ទាន់ នៅពេលដែលពួកគេរកឃើញសកម្មភាពនេសាទខុសច្បាប់

ឡើយ ។ ប៉ុន្តែសិទ្ធិនៃការការពារខ្លួនបែបនេះចាំបាច់ណាស់ ប្រសិនបើពុំមានអាជ្ញាធរ ដើម្បីការពារសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ ( មាត្រា ៤៤ I ១ និង II CC) នៅខណៈនេះប្រកបដោយប្រសិទ្ធភាពទេនោះ[២៤] ។

### ៣) គោលបំណងនៃការដាក់កំហិតដែលមិនស្របតាមរដ្ឋធម្មនុញ្ញ

នៅពេលដែលអ្នកធ្វើច្បាប់ដាក់កំរិតលើករណីយកិច្ច ឬការហាមឃាត់ ការធ្វើបែបនេះកំណត់នូវការប្រើសេរីភាពរបស់អ្នកដែលបានទទួលរងផលប៉ះពាល់ជាប្រចាំ ។ ដូច្នេះហើយ ទើបគេត្រូវការសេចក្តីព្យាយាមដ៏ខ្លាំងក្លា ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីការហាមឃាត់ និងករណីយកិច្ចនៅក្នុងអត្ថបទច្បាប់ ។ ការដាក់កំហិតលើសេរីភាព និងសិទ្ធិមនុស្ស មិនអាចធ្វើឡើងតាមវិធីមួយដែលគ្មានព្រំដែនបានទេ ប៉ុន្តែ ត្រូវអនុវត្តតាមលក្ខខណ្ឌមួយចំនួន ។ អ្នកធ្វើច្បាប់គ្រប់រូបត្រូវគិតថា **ការដាក់កំហិតរបស់ខ្លួនត្រូវបានធ្វើឡើង ដោយគោរពទៅតាមគោលបំណងដែលត្រូវបានអនុញ្ញាត និងអនុម័តដោយរដ្ឋធម្មនុញ្ញកម្ពុជា ឬអនុសញ្ញាអន្តរជាតិណាមួយ** ។ គ្រោះថ្នាក់នៅត្រង់ចំណុចនោះគឺថា អ្នកធ្វើច្បាប់ទាមទារដើម្បីដាក់កំហិតលើសេរីភាព សំរាប់គោលបំណងមួយដែលមិនមានចែងច្បាស់លាស់ នៅក្នុងអត្ថបទស្តីពីសិទ្ធិមនុស្សពិសេសនៃរដ្ឋធម្មនុញ្ញកម្ពុជា ឬនៅក្នុងប្រការស្តីពីការដាក់កំហិតទូទៅនៅក្នុង មាត្រា៣១ II ២ CC ។

<u>ឧទាហរណ៍:</u>

មាត្រា ១២ I នៃច្បាប់សារព័ត៌មាន អនុវត្តតាមគោលបំណងនៃការដាក់កំហិត ដែលមិនស្របតាមរដ្ឋធម្មនុញ្ញ : មាត្រា ១២ I នៃច្បាប់សារព័ត៌មាន ហាមឃាត់ការបោះពុម្ពផ្សាយនូវពត៌មានណាដែលប៉ះពាល់ដល់ "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ" ។ ដូច្នេះ សេរីភាពនៃការបញ្ចេញមតិ ត្រូវបានកំណត់មិនត្រឹមតែដើម្បីគោលបំណងការពារ "សន្តិសុខជាតិ" ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំង ដើម្បីគោលបំណងការពារ "ស្ថេរភាពនយោបាយ" ទៀតផង ។ ផ្ទុយទៅវិញ យោងតាមមាត្រា៤១ I ២ CC និងមាត្រា១៩ III ក)ខ) ICCPR សេរីភាពនៃការបញ្ចេញមតិ អាចត្រូវបានកំណត់ដោយអ្នកធ្វើច្បាប់ដើម្បីគោលបំណងការពារ "សន្តិសុខជាតិ" <u>តែប៉ុណ្ណោះ</u> ។ មាត្រាទាំងនេះ <u>មិន</u>រាប់បញ្ចូលនូវការអនុញ្ញាតឱ្យអ្នកធ្វើច្បាប់ ដាក់កំហិតលើសេរីភាពនេះដើម្បីគោលបំណងការពារ "ស្ថេរភាពនយោបាយ" ឡើយ ។

### ៤) ភាពវិសមាមាត្រនៃការដាក់កំហិតលើសិទ្ធិមនុស្ស

លើសពីនេះទៀត ការដាក់កំហិតត្រូវតែមានសមាមាត្រ មានន័យថា មិនហួសពីព្រំដែននៃភាពចាំបាច់ ។ ចំណុចនេះធ្វើឱ្យមានការចាំបាច់ ( "គោលការណ៍នៃភាពសមាមាត្រ" ) ។

អ្នកធ្វើច្បាប់ មានវិធានការផ្សេងៗដើម្បីបញ្ញត្តិអំពីអាកប្បកិរិយារបស់បុគ្គលដែលជាកម្មវត្ថុនៃច្បាប់ ដោយធ្វើការដាក់កំហិតលើសេរីភាពរបស់ពួកគេក្នុងកំរិតផ្សេងៗគ្នា ។ ជាឧទាហរណ៍ អ្នកធ្វើច្បាប់ អាចបញ្ញត្តិអំពីការហាមប្រាមជាទូទៅលើសកម្មភាពមួយ ។ ការហាមប្រាមនេះ អាចជាការដាក់កំហិតកំរិតធ្ងន់បំផុត ។ ឬពួកគេអាចធ្វើការហាមឃាត់ដល់សកម្មភាពមួយ ប៉ុន្តែត្រូវតែមានករណីលើកលែងចំពោះការហាមឃាត់នោះដែរ ។ នេះជាការដាក់កំហិតដែលមានលក្ខណៈធូរស្រាលបន្តិច ។ គ្រោះថ្នាក់នៅត្រង់ថា អ្នកធ្វើច្បាប់ មិនគិតអំពីវិធានការស្រាលៗដែលអាចជ្រើសរើសយកមកប្រើទេ ហើយពួកគេបែរជាបញ្ញត្តិពីការដាក់កំហិត និងកាតព្វកិច្ចដែលមាន

[២៤] សូមមើល របាយការណ៍របស់អង្គការ Oxfam ដែលបានបញ្ជាក់ខាងលើ ទំព័រ ៣៤,៣៥ : ដំណើរការពិគ្រោះយោបល់បានផ្តល់នូវសំណើរមួយដែលត្រូវបន្ថែមលើ មាត្រា៧៧ E) និងF) ដែលបានផ្តល់នូវសិទ្ធិនេះយ៉ាងច្បាស់លាស់ ។

លក្ខណៈធ្ងន់ធ្ងរ ហួសពីភាពចាំបាច់ទៅវិញ ។ វិធានការខាងក្រោមនេះ ចាប់ផ្តើមពីការដាក់កំហិត ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត និងបញ្ចប់ដោយការដាក់កំហិតស្រាលបំផុត ។ អ្នកធ្វើច្បាប់ តែងតែត្រូវជ្រើសរើសវិធានការដាក់កំហិតស្រាលៗដែលអាចធ្វើទៅបាន លើសិទ្ធិរបស់បុគ្គលដែលជាកម្មវត្ថុនៃច្បាប់ ។




- **ការហាមឃាត់ទូទៅ** នូវសកម្មភាពមួយ **ដោយគ្មានការលើកលែង**:

  (=វិធានការដ៏តឹងរឹងបំផុតៈ **គ្មានសិទ្ធិទាល់តែសោះ** ក្នុងការធ្វើសកម្មភាព)

  ឧទាហរណ៍:

  ការហាមប្រាមចំពោះការញុះញង់ឱ្យមានការស្អប់ខ្ពើមពូជសាសន៍ ឬចំពោះការធ្វើទារុណកម្ម មិនមានការលើកលែងឡើយ ពីព្រោះសកម្មភាពដែលត្រូវបានគេហាមឃាត់ទាំងនេះ គឺជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលមិនអាចទទួលយកបាន (សូមមើល មាត្រា២៦ ឃ្លាទី២ ICCPR: "រាល់"ការរើសអើង ត្រូវបានហាមឃាត់ ។ សូមមើលផងដែរ មាត្រា២ II អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មៈ ទោះបីជាសង្គ្រាម ឬសន្តិសុខជាតិក៏ដោយ មិនត្រូវយកមកធ្វើជាលេសដើម្បីធ្វើទារុណកម្មឡើយ) ។

- **ការហាមឃាត់ទូទៅ** ចំពោះសកម្មភាពមួយ ជាមួយលទ្ធភាពនៃ**ការអនុញ្ញាតនៃការលើកលែង**:

  (= ស្រាលជាងការហាមឃាត់ទូទៅៈ សកម្មភាពទូទៅ ត្រូវបានហាមឃាត់ ប៉ុន្តែមាន**ការអនុញ្ញាតលើកលែង**សំរាប់សកម្មភាពដែលអាចធ្វើទៅបាន)

  ឧទាហរណ៍:

  ជាទូទៅ បុគ្គលគ្រប់រូបត្រូវបានហាមប្រាមមិនឱ្យកាន់កាប់ និងប្រើប្រាស់អាវុធ ពីព្រោះអាវុធ ជាធម្មតាមានគ្រោះថ្នាក់ណាស់ ហើយការប្រើប្រាស់អាវុធជាទូទៅមិនអាចដោះស្រាយទំនាស់បានទេ ក៏ប៉ុន្តែ វាបង្កើតនូវការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ។ ប៉ុន្តែ មានស្ថានភាពមួយចំនួន ដែលធ្វើឱ្យការប្រើប្រាស់អាវុធមានការចាំបាច់ ។ អាស្រ័យហេតុនេះ ច្បាប់ត្រូវតែបើកចំហដើម្បីផ្តល់នូវការលើកលែងខ្លះ ដល់ស្ថានភាពមួយចំនួនដែលមានព្រំដែនកំណត់ទាំងនេះ ដូចជា ច្បាប់ត្រូវតែសម្រួលដល់ការទទួលលិខិតអនុញ្ញាតកាន់កាប់អាវុធដែលលើកលែងមួយ សំរាប់អ្នកដែលបានទទួលការគំរាមកំហែងដល់ជីវិត និងអ្នកដែលធ្វើការជាកងការពារនៃទីភ្នាក់ងារដឹកជញ្ជូនប្រាក់ជាដើម ។ (សូមមើលផងដែរ មាត្រា៩ II នៃពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវៈ ករណីលើកលែងក្នុងការកាន់អាវុធសំរាប់អង្គរក្សនៃប្រមុខរដ្ឋបរទេស) ។

- **ករណីយកិច្ច**ដើម្បីទទួល**ការអនុញ្ញាត**ជាមុនៈ

  (= ការទប់ស្កាត់បង្ការៈ **សកម្មភាពត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌនៃការសុំការអនុញ្ញាតជាមុន**)

  ឧទាហរណ៍:

  សកម្មភាពទាំងឡាយ ដូចជាការសាងសង់ផ្ទះ ឬការបើកបររថយន្ត គឺជាការប្រើសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិឯកជន ឬសិទ្ធិសេរីភាពនៃការធ្វើដំណើរដោយសេរី ដែលអាចទទួលយកបានជាទូទៅ ។ ដូច្នេះ សិទ្ធិទាំងនេះត្រូវតែត្រូវបានគេផ្តល់ឱ្យ ។ ប៉ុន្តែ ការបើកបររថយន្ត អាចមានគ្រោះថ្នាក់ ពីព្រោះ វាអាច

បណ្តាលឱ្យមានឧបទ្ទវហេតុ ។ ឬម្យ៉ាងវិញទៀត ការកសាងផ្ទះអាចមានគ្រោះថ្នាក់ ប្រសិនបើ គេមិនគោរពច្បាប់នៃការសាងសង់ប្រកបដោយសុវត្ថិភាព ហើយផ្ទះនោះរលំ ។

ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ទាំងនេះ គេចាំបាច់ត្រូវកំណត់នូវការអនុវត្តនីសកម្មភាពទាំងនោះ ហើយផ្តល់សិទ្ធិតែក្នុងលក្ខខណ្ឌមួយដែលអាជ្ញាធរបានពិនិត្យជាមុន និងបង្ហាញថា សកម្មភាពទាំងនោះពុំមានគ្រោះថ្នាក់ទេ ។

អ្នកធ្វើច្បាប់ ត្រូវធានានូវការពិនិត្យជាមុនបែបនេះ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវភាពចាំបាច់នៃលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណណាមួយ ការអនុញ្ញាតឱ្យបើកបររថយន្ត អាចផ្តល់ឱ្យបានតែក្នុងលក្ខខណ្ឌដែលថាបុគ្គលទាំងនោះបានប្រឡងជាប់ការធ្វើតេស្តជាមុន ដែលរៀបចំឡើងដោយអាជ្ញាធរដែលបានពិនិត្យមើលសមត្ថភាពគ្រប់គ្រងរថយន្ត និងការយល់ដឹងពីច្បាប់ចរាចររបស់បុគ្គលទាំងនោះតែប៉ុណ្ណោះ (សូមមើលមាត្រា២៩ I និង VI នៃច្បាប់ស្តីពីចរាចរផ្លូវគោក) ។ ការអនុញ្ញាត ក៏អាចចេញឱ្យតែ ក្នុងលក្ខខណ្ឌមួយចំនួនតែប៉ុណ្ណោះ ដូចជា ប័ណ្ណបើកបរសំរាប់រថយន្តធំៗ អាចចេញឱ្យដល់អ្នកបើកបរដែលមានវ័យចំណាស់ និងមានបទពិសោធន៍តែប៉ុណ្ណោះ ។ ការអនុញ្ញាតក្នុងការសាងសង់ផ្ទះ អាចផ្តល់ឱ្យបានលុះត្រាណានាយកដ្ឋានសំណង់ បានពិនិត្យមើលប្លង់នៃការសាងសង់នោះ ។ ឬលិខិតអនុញ្ញាតសាងសង់ អាចចេញឱ្យបានលុះត្រាតែការសាងសង់នេះ រក្សាចម្ងាយមួយជាក់លាក់ពីផ្ទះអ្នកជិតខាង ។

ការសុំអនុញ្ញាតបែបនេះ មិនមែនមានន័យថា ជាអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធរក្នុងការអនុញ្ញាត ឬអត់នោះទេ ។ អាជ្ញាធរ ត្រូវចេញលិខិតអនុញ្ញាត នៅពេលដែលលក្ខខណ្ឌទាំងឡាយត្រូវបានបំពេញ! ជនណាក៏ដោយ មាន**សិទ្ធិទទួលបាននូវការអនុញ្ញាត** នៅពេលដែលគាត់អាចបញ្ជាក់ថា សកម្មភាពរបស់គាត់មិនមានគ្រោះថ្នាក់!

ក្នុងករណីដែលសកម្មភាពមួយ មិនមានគ្រោះថ្នាក់ជាទូទៅនោះ វាអាចមិនមានសមាមាត្រឡើយក្នុងការដាក់លក្ខខណ្ឌឱ្យការសុំការអនុញ្ញាតជាមុន ។ ដូចជា ការប្រើសេរីភាពនៃការបញ្ចេញមតិ ជានិច្ចកាលតែងតែមិនមានគ្រោះថ្នាក់ឡើយ ។ ដូច្នេះ ការត្រួតពិនិត្យជាមុន ដែលមានន័យថា ការត្រួតពិនិត្យជាមុនលើសុន្ទរកថា ឬការបោះពុម្ពផ្សាយនោះ មិនត្រូវបានអនុញ្ញាតឡើយ (សូមមើលមាត្រា៣ នៃច្បាប់ស្តីពីសារព័ត៌មាន) ពីព្រោះវានឹងកំណត់នូវសេរីភាពនេះក្នុងលក្ខណៈវិសមាមាត្រ ។ វានឹងមានលក្ខណៈគ្រប់គ្រាន់ប្រសិនបើ ច្បាប់សារពត៌មាននេះផ្តល់នូវបទបញ្ញត្តិដែលអនុញ្ញាតឱ្យអង្គនីតិប្រតិបត្តិ ឬតុលាការ ចាត់វិធានការក្នុងករណីបំពានសិទ្ធិនៃការបញ្ចេញមតិ បានកើតឡើងយ៉ាងពិតប្រាកដនោះ ។

- **ករណីយកិច្ច**ក្នុងការ**ជូនដំណឹង**ដល់អាជ្ញាធរជាមុន មុនពេលចាប់ផ្តើមសកម្មភាព:

(= វិធានការនៃការទប់ស្កាត់បង្ការដ៏ស្រាលបំផុត: **សកម្មភាពត្រូវបានអនុញ្ញាត បន្ទាប់ពីមានការបង្ហាញជាមុន**)

ឧទាហរណ៍:

ការរៀបចំការប្រមូលផ្តុំគ្នាជាសាធារណៈ (បាតុកម្ម) តាមធម្មតា មិនមែនជាសកម្មភាពមួយដែលប្រកបដោយគ្រោះថ្នាក់ឡើយ ។ ម្យ៉ាងវិញទៀត វាគឺជាសិទ្ធិធ្វើបាតុកម្មមួយ មាត្រា៤១ I ១ CC ។ ដូច្នេះជាទូទៅ វាជាការស្របច្បាប់ក្នុងការប្រើសិទ្ធិនេះ ។ ប៉ុន្តែ វាតែងតែមានឱកាស និងភាពដែលអាចកើតឡើងបានដែលថា ការប្រមូលផ្តុំគ្នាមួយអាចក្លាយទៅជាមានគ្រោះថ្នាក់ ។ ហ្វូងមនុស្សដ៏ធំមួយអាចបាត់បង់វិន័យបាន គ្រប់គ្រងស្ថានភាពមិនបាន ហើយចាប់ផ្តើមជាមួយដែលសកម្មភាពប្រាសចាកសន្តិភាព (សូមមើល

កុប្បកម្មប្រឆាំងជនជាតិថៃនៅក្នុងទីក្រុងភ្នំពេញ នៅក្នុងខែមករា ឆ្នាំ២០០៣ ដែលចាប់ដោយសន្តិវិធី ហើយបានបញ្ចប់ទៅវិញដោយអំពើហិង្សានៃហ្វូងមនុស្ស) ។ អាស្រ័យហេតុនេះ វាជាការចាំបាច់ណាស់ដែលអាជ្ញាធរត្រូវចាត់វិធានការប្រុងប្រយ័ត្នចាំបាច់ជាមុន ដើម្បីទប់ស្កាត់អំពើហិង្សា និងដើម្បីការពារសិទ្ធិរបស់អ្នកដទៃ ។ ដោយអាជ្ញាធរ និងនគរបាលអាចធ្វើដូចខាងលើបាន លុះត្រាតែពួកគេដឹងពីពេលវេលា និងទីកន្លែងដែលបាតុកម្មនឹងប្រព្រឹត្តិទៅនោះ គេចាំបាច់ត្រូវជូនដំណឹងដល់ពួកគេអំពីព្រឹត្តិការណ៍ទាំងនេះជាមុន ។ ដើម្បីធានានូវការជូនដំណឹងដល់អាជ្ញាធរឱ្យបានទាន់ពេលវេលាបែបនេះ អ្នកធ្វើច្បាប់ដាក់កំណត់នូវករណីយកិច្ចមួយក្នុងការជូនដំណឹងដល់អាជ្ញាធរ ។ ការធ្វើបែបនេះ ផ្តល់នូវឱកាសមួយដល់ពួកគេ ដើម្បីចាត់វិធានការការពារជាមុន ដើម្បីការពារបាតុកម្មពីការរំខានដោយបាតុកម្មប្រឆាំង ដើម្បីពង្រាយកម្លាំងនគរបាល ដើម្បីការពារទ្រព្យសម្បត្តិរបស់អាជីវករនៅតាមដងផ្លូវ និងដើម្បីធ្វើការរៀបចំចាំបាច់ ដើម្បីដាក់ផ្លាកសញ្ញាចរាចរណ៍តាមដងផ្លូវ ។ ម្យ៉ាងវិញទៀត ការបង្ហាញឱ្យដឹងជាមុនអំពីការធ្វើបាតុកម្ម ផ្តល់នូវឱកាសមួយដល់អាជ្ញាធរ ដើម្បីពិនិត្យមើលថា តើមានការចាំបាច់ដើម្បីហាមប្រាមបាតុកម្មដែរឬទេ? ដូចជា បាតុកម្មមួយដែលអាចត្រូវបានអាជ្ញាធរហាមប្រាម គឺបាតុកម្មដែលអំពាវនាវឱ្យមានអំពើហិង្សាយ៉ាងច្បាស់លាស់ ឬអនុវត្តតាមគោលបំណងពូជសាសន៍និយម ដែលរំលោភសិទ្ធិមនុស្សរបស់ជនជាតិភាគតិច (ដូចជា បាតុកម្មប្រឆាំងជនជាតិវៀតណាមទាំងអស់នៅក្នុងប្រទេសកម្ពុជា)[២៥] ។

អាស្រ័យហេតុនេះ អ្នកធ្វើច្បាប់បានដាក់កំណត់នូវករណីយកិច្ចមួយ ក្នុងការជូនដំណឹងដល់អាជ្ញាធរជាមុន អំពីបាតុកម្មដែលបានគ្រោងនឹងប្រព្រឹត្តិទៅនៅតាមផ្លូវសាធារណៈ (មើល មាត្រា២ III នៃច្បាប់ស្តីពីបាតុកម្ម) ។ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងនេះហើយ អាជ្ញាធរ អាចពិនិត្យ និងសម្រេចថា តើពួកគេត្រូវចេញបំរាមដល់បាតុកម្មនេះ ព្រោះមានសញ្ញាគ្រោះថ្នាក់នៃអំពើហឹង្សាយ៉ាងច្បាស់លាស់ដែរឬទេ (មើល មាត្រា៣ I នៃច្បាប់ស្តីពីបាតុកម្ម) ។ ប្រសិនបើ ករណីកិច្ចក្នុងជូនដំណឹងនេះ ត្រូវបានគេរំលោភ ហើយបាតុកម្មប្រព្រឹត្តិទៅដោយគ្មានការជូនដំណឹងទេនោះ នគរបាលអាចបញ្ឈប់បាតុកម្មនេះបាន (មាត្រា៤ I នៃច្បាប់ស្តីពីបាតុកម្ម) ។

ដូច្នេះ ករណីយកិច្ចក្នុងការជូនដំណឹងជាមុន ផ្តល់ឱកាសដល់អាជ្ញាធរ ដើម្បី ចាត់វិធានការប្រុងប្រយ័ត្នជាមុន និងដើម្បីធ្វើអន្តរាគមន៍ក្នុងករណីដែលសកម្មភាពស្របច្បាប់មួយ ក្លាយទៅជាសកម្មភាពប្រកបដោយគ្រោះថ្នាក់ ។

**ចូរកត់សំគាល់: "ជូនដំណឹង"ដល់អាជ្ញាធរ មិនមានន័យថាជាការសុំការអនុញ្ញាតនោះទេ!**

លក្ខខណ្ឌ សំរាប់ឱ្យសកម្មភាពមួយអាចធ្វើទៅបានដោយស្របច្បាប់ទាល់តែធ្វើការជូនដំណឹងជាមុនដល់អាជ្ញាធរ គឺជាការដាក់កំហិតមួយធូរស្រាលជាង លក្ខខណ្ឌដែលចែងដោយច្បាប់ដែលថា សកម្មភាពមួយអាចធ្វើទៅបានដោយស្របច្បាប់ ទាល់តែមានការអនុញ្ញាតជាមុនដោយអាជ្ញាធរ ។ អ្នកដែលត្រូវជូនដំណឹងដល់អាជ្ញាធរ អាចចាប់ផ្តើមសកម្មភាពរបស់គាត់ដោយស្របច្បាប់ បន្ទាប់ពីការជូនដំណឹង ។ វាអាស្រ័យលើអាជ្ញាធរដែលអ្នកសំរេចថា ត្រូវធ្វើអន្តរាគម និងបញ្ឈប់គាត់ ឬអត់នោះ ។ អ្នកដែលត្រូវទទួលការអនុញ្ញាតមិនអាចចាប់ផ្តើមសកម្មភាពរបស់ខ្លួនដោយគ្មានការអនុញ្ញាតនោះបានទេ ហើយគាត់ត្រូវរងចាំការសំរេចរបស់អាជ្ញាធរនោះ ។

[២៥] មើលសៀវភៅរបស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ស្តីពី "ការពិចារណាពិស្តារផ្នែកគតិយុត្តិ - សិទ្ធិមនុស្ស" ទំព័រទី ៦៥ ដល់ ៦៧

- ការអនុញ្ញាតរបស់អាជ្ញាធរសំរាប់**ការធ្វើអន្តរាគមន៍ជាតាមក្រោយ** ក្នុងករណីរំលោភសិទ្ធិ
(= វិធានការដ៏ទន់ភ្លន់បំផុតដែលអាចធ្វើទៅបានៈ **ឱកាសនៃការដាក់កំហិត បន្ទាប់ពីសកម្មភាពមួយត្រឡប់ទៅជាខុសច្បាប់**)

ឧទាហរណ៍ៈ

តាមធម្មតាច្បាប់មានជំនឿថា មនុស្សនឹងប្រើសិទ្ធិសេរីភាពរបស់ខ្លួន ដោយមធ្យោបាយសន្តិភាព និងគ្មានគ្រោះថ្នាក់ ។ ដូច្នេះ ការដាក់កំហិត ត្រូវបានធ្វើឡើងតែក្នុងករណីដែលមនុស្សមិនបានបំពេញសេចក្តីរំពឹងទុកនោះ ហើយរំលោភច្បាប់តែប៉ុណ្ណោះ ។

ដូចជា ពង្រាងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារផ្តល់ការអនុញ្ញាតឱ្យ នគរបាលបញ្ជូនប្តីម្នាក់ចេញពីផ្ទះរបស់គាត់បាន បន្ទាប់ពីគាត់បានប្រើអំពើហិង្សាទៅលើប្រពន្ធ និងកូនរបស់ខ្លួន ។ ឬក្រមព្រហ្មទណ្ឌ អនុញ្ញាតឱ្យតុលាការដាក់ទណ្ឌកម្មដល់មនុស្សទាំងឡាយ បន្ទាប់ពីពួកគេបានបំពានសិទ្ធិសេរីភាពរបស់ខ្លួន និងបានបង្កការខូចខាតដល់អ្នកដទៃ ។

វិធានការទាំងអស់នេះ ត្រូវបានហៅថា វិធានការត្រួតពិនិត្យបង្ក្រាប ។ ខុសពីការត្រួតពិនិត្យបង្ការដែលត្រូវបានអនុវត្តជាមុន វិធានការបង្ក្រាប ត្រូវបានយកមកអនុវត្តនៅក្រោយពេលសកម្មភាពមួយបានក្លាយជាសកម្មភាពខុសច្បាប់ និងបន្ទាប់មក ធ្វើការបង្ក្រាប (ដូចជា ធ្វើការផ្តន្ទាទោស ឬ ដាក់ទណ្ឌកម្ម) សកម្មភាពខុសច្បាប់នោះតែម្តង ។

# ភាពសមាមាត្រនៃការដាក់កំហិតលើសិទ្ធិ ដែលមានចែងនៅក្នុងច្បាប់

- ច្បាប់ដាក់កំហិតទៅលើសកម្មភាពមួយចំនួនរបស់មនុស្សម្នាក់ដើម្បីការពារសិទ្ធិរបស់មនុស្សម្នាក់ទៀត
- ទំហំនៃដាក់កំហិត អាស្រ័យទៅលើសកម្មភាព តើសកម្មភាពនោះគ្រោះថ្នាក់យ៉ាងណា?

| | | | | | |
|---|---|---|---|---|---|
| តើសកម្មភាពនោះគ្រោះថ្នាក់ដោយរបៀបណា? | សកម្មភាព =ដែលគ្រោះថ្នាក់បំផុត និង រំលោភសិទ្ធិមនុស្ស ដែលមានលក្ខណៈធ្ងន់ធ្ងរ<br><br>ឧទាហរណ៍:<br>- ធ្វើទារុណកម្មទៅលើមនុស្ស<br>- លើកដំកើងឱ្យមានការស្អប់ពូជសាសន៍ណាមួយ | សកម្មភាព =ជាទូទៅគ្រោះថ្នាក់ខ្លាំងតែមានករណីលើកលែងអាចទទួលយកបាន<br><br>ឧទាហរណ៍:<br>- ការប្រើប្រាស់អាវុធ | សកម្មភាព =អាចគ្រោះថ្នាក់នៅពេលដែលកិតជាមូលដ្ឋានណាមួយមិនត្រូវបានគេបំពេញ<br><br>ឧទាហរណ៍:<br>- ការបើកបររថយន្ត<br>- ការសាងសង់អាគារ | សកម្មភាព =មិនគ្រោះថ្នាក់តែឱកាសណាមួយអាចក្លាយជាគ្រោះថ្នាក់<br><br>ឧទាហរណ៍:<br>-ការធ្វើបាតុកម្មដោយសន្តិវិធី | សកម្មភាព = មិនគ្រោះថ្នាក់ មិនគ្រោះថ្នាក់ទាល់តែសោះ ប៉ុន្តែអាចត្រូវគេរំលោភបំពាន<br><br>ឧទាហរណ៍:<br>ការអនុវត្តន៍សេរីភាពក្នុងការបញ្ចេញមតិ |
| ទំហំនៃការដាក់កំហិត | ការដាក់កំហិតធ្ងន់ធ្ងរបំផុតតាមដែលអាចធ្វើទៅបាន → | មិនសូវធ្ងន់ធ្ងរ → | ស្រាល → | ស្រាលជាងបន្តិច → | ស្រាលបំផុត |
| វិធានការនីតិបញ្ញត្តិ | ការដាក់កំហិតទូទៅ ដោយគ្មានការលើកលែងណាមួយទេ<br><br>(គ្មានសិទ្ធិដើម្បីធ្វើសកម្មភាពអ្វីមួយឡើយ) | ហាមឃាត់ ប៉ុន្តែអាចមានការអនុញ្ញាតលើកលែងដែលអាចធ្វើទៅបាន<br><br>(សិទ្ធិដែលត្រូវលើកលែង) | ករណីយកិច្ចទទួលបានការអនុញ្ញាតជាមុន<br>ផ្តល់ឱកាសឱ្យអាជ្ញាធរ ដើម្បីពិនិត្យសកម្មភាពជាមុន<br>(សិទ្ធិទទួលបាននូវការអនុញ្ញាតនៅពេលដែលបទដ្ឋានសន្តិសុខណាមួយត្រូវបានបំពេញ) | ករណីយកិច្ចជូនដំណឹង<br>ផ្តល់ឱកាសឱ្យអាជ្ញាធរ ពិនិត្យនិងសំរេចអំពី ភាពចាំបាច់នៃការហាមឃាត់<br>(សិទ្ធិធ្វើសកម្មភាពបន្ទាប់ពីបញ្ជាក់ថាអ្នកណាម្នាក់នឹងអនុវត្តសិទ្ធិ) | ការអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ជាក្រោយក្នុងករណីមានការរំលោភបំពាន<br><br>(គ្មានការកំណត់សិទ្ធិ តែអាចទទួលវិន័យ) |
| | ឧទាហរណ៍:<br>- មាត្រា២ II អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម<br>- មាត្រា ២៦ ឃ្លាទី ២ ICCPR | ឧទាហរណ៍:<br>អាវុធ អនុញ្ញាតចំពោះតែអង្គរក្ស (មាត្រា៨ II នៃពង្រាងច្បាប់ស្តីពីអាវុធជាតិផ្ទុះ) | ឧទាហរណ៍:<br>- ប័ណ្ណបើកបររថយន្ត<br>- ការអនុញ្ញាតសាងសងអគារ | ឧទាហរណ៍:<br>មាត្រា២ III នៃច្បាប់ស្តីពីបាតុកម្ម | ឧទាហរណ៍:<br>គ្មានការត្រួតពិនិត្យជាមុនទេ ចំពោះសេរីភាពក្នុងការនិយាយស្តី ប៉ុន្តែអាចទទួលវិន័យក្នុងករណីបរិហារកេរ្តិ៍ |